# ឯកសារគោលជំហរ

ខែវិច្ឆិកា ២០២១

## ធាតុចូលរបស់អង្គការសង្គមស៊ីវិលសម្រាប់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩ -២០២៣

## សារតារ

រាជរដ្ឋាភិបាលកម្ពុជាបានអញ្ជើញអង្គការសង្គមស៊ីវិលឱ្យផ្ដល់ធាតុចូលដល់ការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ នៅចុងឆ្នាំ២០១៨ ហើយនៅក្នុងការត្រួតពិនិត្យពាក់កណ្ដាលអាណត្តិនេះ អង្គការសង្គមស៊ីវិលក៏ត្រូវបានស្វែងរកដើម្បីចូលរួមផងដែរ។ អង្គការសង្គមស៊ីវិលចូលរួមយ៉ាងសកម្មក្នុងការធ្វើការជាមួយអ្នកបង្កើតគោលនយោបាយឱ្យទទួលខុសត្រូវលើការប្ដេជ្ញាចិត្តប្រកបដោយតម្លាភាព និងមានលក្ខណៈប្រកបដោយបរិយាប័ន្នក្នុងដំណើរការត្រួតពិនិត្យនិងវាយតម្លៃ។ អង្គការសង្គមស៊ីវិលបានបង្ហាញពីបំណងប្រាថ្នានៃការចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការទាំងមូលនៃការអនុវត្តផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងសម្រាប់ការអនុវត្តយុទ្ធសាស្រ្តចតុកោណ ក្រោមការសម្របសម្រួលរបស់ក្រសួងផែនការ (MoP) និងកិច្ចសហការពីតួអង្គអភិវឌ្ឍន៍ទាំងអស់។

នៅក្នុងដំណើរការទាំងមូលនៃការត្រួតពិនិត្យពាក់កណ្ដាលអាណត្តិនេះមានអង្គការសង្គមស៊ីវិលជាង ១០០ (អង្គការជាតិ និងអន្តរជាតិ) ដែលបាននិងកំពុងធ្វើការនៅទូទាំងប្រទេសកម្ពុជាបានចូលរួមយ៉ាងសកម្ម ក្នុងការផ្ដល់នូវធាតុចូលតាមរយៈកិច្ចសន្ទនាជាបន្តបន្ទាប់ដែលរៀបចំនិងសម្របសម្រួលដោយអង្គការ NGOF និងCCC ។ ធាតុចូលសំខាន់ៗទាំងនោះសម្រាប់ NSDP 2019-2023 រួមមានដូចខាងក្រោម៖

## សមិទ្ធផលសំខាន់ៗ

### ការពន្លឿនកែទម្រង់អភិបាលកិច្ច

- រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាចិត្ត និងបង្ហាញពីវឌ្ឍនភាពសំខាន់ៗលើវិមជ្ឈការដូចជា វិមជ្ឈការអំណាច ធនធាន និងការកសាងសមត្ថភាពត្រូវបានបង្វែរទៅថ្នាក់ក្រោមជាតិ។ ឧទាហរណ៍ ការបង្កើនថវិកាប្រចាំឆ្នាំសម្រាប់ឃុំ សង្កាត់ ការផ្ទេរមុខងារសម្រាប់វិស័យសុខាភិបាល និងអប់រំ បង្កើនការផ្សព្វផ្សាយសេវាសាធារណៈដល់ប្រជាពលរដ្ឋ យន្តការនានាត្រូវបានបង្កើតឡើងដើម្បីលើកកម្ពស់ការចូលរួមជាសាធារណៈ និងបង្កើនការដោះ

ស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និងការកើនឡើងបន្តិចម្តងៗនៃចំនួនស្ត្រីដែលបានកាន់តួនាទីជាអ្នកដឹកនាំក្នុងកិច្ចការសាធារណៈនៅគ្រប់កម្រិត។

- កិច្ចសហការជាវិជ្ជមាន ជាមួយដៃគូអភិវឌ្ឍន៍ក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពដល់ថ្នាក់ក្រោមជាតិរបស់រដ្ឋាភិបាល។
- វាច្បាស់ណាស់ដែលថាប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងហេដ្ឋារចនាសម្ព័ន្ធត្រូវបានបំពាក់គួរឱ្យកត់សម្គាល់ ព្រមទាំងការប្រើប្រាស់យ៉ាងទូលំទូលាយនៃព័ត៌មានឌីជីថល ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍយ៉ាងឆាប់រហ័សនៃឧស្សាហកម្មពិភពលោក ៤.០ ។
- ការកែលម្អផ្លូវសាធារណៈ និងការខិតខំប្រឹងប្រែងឥតឈប់ឈរដែលត្រូវបានដាក់ជាទិសដៅអាទិភាព ដើម្បីទាក់ទាញវិនិយោគិន។

## បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រ

- រាជរដ្ឋាភិបាលបានបញ្ជាក់ពីការប្តេជ្ញាចិត្តដើម្បីលើកកម្ពស់កិច្ចសន្ទនាពហុស្ថាប័នពាក់ព័ន្ធនៅគ្រប់កម្រិត។ រាជរដ្ឋាភិបាលកម្ពុជាសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនៅគ្រប់កម្រិត ដែលជារឿងវិជ្ជមានដែលត្រូវធ្វើសម្រាប់ការលើកទឹកចិត្តឱ្យមានការចូលរួមជាសាធារណៈ។ តាមរយៈយុទ្ធសាស្ត្រជាដៃគូនិងកិច្ចសហប្រតិបត្តិការសម្រាប់ការងារអភិវឌ្ឍន៍ រដ្ឋាភិបាលដាក់ចេញជាយន្តការជាគន្លឹះជាច្រើនដើម្បីជំរុញភាពជាដៃគូនៅទាំងថ្នាក់ជាតិនិងក្រោមជាតិ ជាពិសេសមានការរៀបចំភាពជាដៃគូចំនួនបីគឺ កិច្ចសន្ទនាពហុស្ថាប័នពាក់ព័ន្ធតាមវិស័យ កិច្ចប្រជុំប្រឹក្សាយោបល់រវាងរាជរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល ព្រមទាំងកិច្ចសន្ទនាជាដៃគូថ្នាក់ក្រោមជាតិ ។
- មានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ចំពោះសន្តិសុខនយោបាយដែលប្រសើរឡើង ពោលគឺគ្មានភាពវឹកវរ និងអំពើហិង្សា។ ការកាន់អំណាចដោយគណបក្សនយោបាយតែមួយមានប្រយោជន៍ចំពោះពេលវេលាដែលសម្រាប់ការអនុម័តច្បាប់។
- យ៉ាងហោចណាស់មានគណបក្សនយោបាយថ្មីចំនួនប្រាំបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃ ដើម្បីចូលរួមក្នុងការបោះឆ្នោតនាពេលខាងមុខ។ ការចុះឈ្មោះអ្នកបោះឆ្នោតទំនងជាកើនឡើងដោយសារតែពលករបំណាកស្រុកត្រឡប់មកវិញក្នុងអំឡុងពេលជំងឺរាតត្បាត។

## ការអភិវឌ្ឍធនធានមនុស្ស

- ប្រទេសកម្ពុជាសម្រេចបាននូវវឌ្ឍនភាពដ៏អស្ចារ្យក្នុងការអប់រំជាមូលដ្ឋាន ដោយទទួលបានការអប់រំកម្រិតបឋមសិក្សាស្ទើរតែជាសកល (ការចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សា ២០១៩-២០២០ មានប្រមាណ៩៨%)។
- មានក្រុមការងារបច្ចេកមួយចំនួនមិនបានធ្វើការត្រឹមត្រូវឬមិនសកម្ម ដែលញ៉ាំងការចូលរួមពីតួអង្គអភិវឌ្ឍន៍នានាមិនសកម្មនិងពេញលេញ ក្នុងការផ្លាស់ប្តូរព័ត៌មាននិងមានបរិយាប័ន្នក្នុងដំណើរការធ្វើសេចក្តីសម្រេច។
- កូវីដ-១៩ បានបង្ខំកុមារកម្ពុជាចេញពីសាលារៀនទូទាំងប្រទេស។ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយដៃគូអភិវឌ្ឍន៍ដើម្បីបន្តផ្តល់ការបង្រៀនពីចម្ងាយក្នុងអំឡុងពេលជំងឺរាតត្បាត។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជននិងកីឡា បានបង្កើតនូវគោលការណ៍ណែនាំមួយ ដែលបង្ហាញពីតួនាទី និងការទទួលខុសត្រូវរបស់គ្រូបង្រៀននៅក្នុងវិស័យនេះនៅដំណាក់កាលដំបូងនៃជំងឺរាតត្បាត។ ក្រសួងអប់រំ យុវជននិងកីឡា បានបង្កើតយុទ្ធសាស្រ្ត ដើម្បីធានាបាននូវវិធានការសុវត្ថិភាពខ្ពស់បំផុត ហើយត្រូវបានដាក់ឱ្យដំណើរការនៅក្នុងសាលារៀននៅកម្ពុជា ដើម្បីបើកដំណើរការដោយប្រុងប្រយ័ត្ន។
- អង្គការអន្តរជាតិខាងការងារ (ILO) បានទទួលការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញឱ្យមានការផ្លាស់ប្តូរសំខាន់ៗនៅក្នុងគន្លងថ្មីនៃការគាំពារសង្គមនៅកម្ពុជា។ អង្គការ ILO បាននិងកំពុងផ្តល់ការគាំទ្រផ្នែកបច្ចេកទេស រួមទាំងការវាយតម្លៃទាក់ទងនឹងអភិបាលកិច្ច និងគោលនយោបាយវិនិយោគ ព្រមទាំងការផ្តល់ការគាំទ្រគ្រប់កម្រិត។ ការគាំពារសង្គមត្រូវបានគ្របដណ្តប់យ៉ាងល្អនៅក្នុងវិស័យផ្លូវការ។ សាខាធានារ៉ាប់រងសុខភាព មាតុភាព និងជំងឺរបស់បេឡាសន្តិសុខសង្គម (បសស) ដែលបានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួនក្នុងឆ្នាំ២០១៦ បានពង្រីកការធានារ៉ាប់រងដល់កម្មករប្រមាណ ២.១ លាននាក់នៅក្នុងវិស័យឯកជនផ្លូវការក្នុងឆ្នាំ២០២០។
- រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តកម្មវិធីផ្ទេរសាច់ប្រាក់ដែលក្រុមគ្រួសារក្រីក្រកម្រិត១ និងកម្រិត២ ទទួលបានអត្ថប្រយោជន៍ក្នុងអំឡុងពេលជំងឺរាតត្បាត។
- បញ្ហាជនមានពិការភាពកំពុងត្រូវបានយកចិត្តទុកដាក់ដោយរាជរដ្ឋាភិបាលកម្ពុជា និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងខេត្តរាជធានីទាំង២៥។

## ការធ្វើពិពិធកម្មសេដ្ឋកិច្ច

- រាជរដ្ឋាភិបាលកម្ពុជាបានបង្កើនថវិកា (៤៤,៤%) សម្រាប់ការវិនិយោគសាធារណៈ ដែលជាភាពវិជ្ជមានក្នុងការជំរុញការអភិវឌ្ឍន៍ផ្អែកលើសេដ្ឋកិច្ច។
- រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបិត្តពន្យារពេលការសាងសង់ទំនប់វារីអគ្គិសនីលើទន្លេមេគង្គរហូតដល់ឆ្នាំ ២០៣០ដែលជាជំហានវិជ្ជមានសម្រាប់ជីវិតសត្វ ធនធានមច្ឆជាតិ ធនធានធម្មជាតិនៃទន្លេមេគង្គ និងប្រជាជនរាប់លាននាក់ដែលជីវភាពរស់នៅរបស់ពួកគេពឹងផ្អែកលើវា។
- អង្គការសង្គមស៊ីវិលត្រូវបានស្វាគមន៍ដោយគណៈកម្មាធិការទន្លេមេគង្គជាតិកម្ពុជា ដើម្បីចូលរួមក្នុងដំណើរការពិគ្រោះយោបល់ស្តីពីការអភិវឌ្ឍលើអាងទន្លេមេគង្គ។
- សូមអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា សម្រាប់អាទិភាពផ្តោតសំខាន់លើការបង្កើនការផលិតថាមពលស្អាត និងកកើតឡើងវិញ ដើម្បីបំពេញតម្រូវការក្នុងស្រុកដែលកំពុងកើនឡើង។

## ការអភិវឌ្ឍប្រកបដោយចីរភាព និង បរិយាប័ន្ន

- រាជរដ្ឋាភិបាលកម្ពុជាបានសាងសង់ប្រព័ន្ធធារាសាស្រ្តខ្នាតធំ និងមធ្យម ជាមួយនឹងកម្ចី និងជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ ដើម្បីផ្តល់លទ្ធភាពដល់កសិករក្នុងការប្រើប្រាស់ទឹកស្រោចស្រព។
- កសិករមាននិន្នាការល្អក្នុងការប្រើប្រាស់ឧបករណ៍កសិកម្មទំនើបដើម្បីបង្កើនផលិតកម្មរបស់ពួកគេ។ ចំនួនកសិករដែលបានអនុវត្តបច្ចេកទេសកសិកម្ម និងការច្នៃប្រឌិតកំពុងកើនឡើង។ ទន្ទឹមនឹងនេះ ការយល់ដឹងរបស់ពួកគេលើការប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិតទំនងជាកើនឡើងផងដែរ។ រីឯចំណេះដឹងបច្ចេកទេសកំពុងកើនឡើងយ៉ាងជាក់ស្តែងក្នុងចំណោមសហគមន៍កសិករ។ ពួកគេត្រូវបានគេមើលឃើញថាមានការកើនឡើងលើសកម្មភាពដំណាំពាណិជ្ជកម្ម និងដំណាំបិញ្ចឹមជីវិតរបស់ពួកគេ ដែលមានភាពធន់នឹងការប្រែប្រួលអាកាសធាតុកាន់តែប្រសើរ។ អង្គការសង្គមស៊ីវិល មើលឃើញថា ការនាំចេញកសិផលកើនឡើងគួរឱ្យកត់សម្គាល់ ស្របនឹងរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។
- រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងកាន់តែខ្លាំងក្នុងការបង្កើត និងពង្រីកព្រៃសហគមន៍/តំបន់ការពារ ដើម្បីកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ។ ដៃគូអភិវឌ្ឍន៍មានការយកចិត្តទុកដាក់ក្នុងការគាំទ្រគំនិតផ្តួចផ្តើមសហគមន៍ស្តីពីការការពារធនធានធម្មជាតិ។
- ក្រសួងអប់រំយុវជន និងកីឡាបានសហការជាមួយក្រសួងបរិស្ថានក្នុងការបង្កើត និងពង្រីកសាលារៀនមេត្រីបរិស្ថាន ដើម្បីបង្ហាញពីការយល់ដឹងអំពីបរិស្ថានក្នុងចំណោមសិស្សានុសិស្សនៅតាមសាលារៀន។

## សារជាគន្លឹះរួមមាន

1. **ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ**ត្រូវបានអនុម័តតាំងពីឆ្នាំ ២០០៨ រីឯ**សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន**បានចូលជាសេចក្តីព្រាងចុងក្រោយរបស់ខ្លួន។ ប៉ុន្តែច្បាប់ទាំងពីរនេះខ្វះការគ្របដណ្តប់គ្រប់ជ្រុងជ្រោយដើម្បីធានាបាននូវការចូលរួមជាសាធារណៈក្នុងការរៀបចំថវិកា និងការចំណាយ។ យន្តការដើម្បីផ្តល់ការត្រួតពិនិត្យលើការចំណាយថវិកាមានកំណត់ក្នុងក្របខ័ណ្ឌច្បាប់នៅថ្នាក់ក្រោមជាតិ តែនៅមានការខ្វះការអនុវត្តជាក់ស្តែង។ **ការចូលរួមជាសាធារណៈនៅក្នុងដំណើរការនៃការរៀបចំថវិកា ឬការចំណាយក៏នៅមាន កម្រិតផងដែរ**។ ការចូលរួមរបស់អង្គការសង្គមស៊ីវិលគឺនៅតែជាបញ្ហាប្រឈមខ្លាំងនៅឡើយ។ ការកសាងទំនុកចិត្តរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលថ្នាក់ក្រោមជាតិ មានសារៈសំខាន់ណាស់ក្នុងការធានាឱ្យមានតម្លាភាព និងគណនេយ្យភាពនៃផលប៉ះពាល់ថវិកា ហើយកិច្ចខិតខំប្រឹងប្រែងនេះគួរតែត្រូវបានគេយកមកពិចារណា។ ជារឿយៗគេសង្កេតឃើញថាមុខងារនៃយន្តការគឺនៅមានកម្រិតនៅឡើយ។ រីឯថវិកា និង ធនធានមនុស្សដើម្បីអនុវត្តយន្តការគឺនៅមានកម្រិតតិចតួចនៅឡើយ។ ការិយាធិបតេយ្យរដ្ឋបាលនៅមានកម្រិតខ្ពស់ ភាពមិនទៀងទាត់ និងអំពើពុករលួយទំនងជានៅតែជាឧបសគ្គដល់ការកែលម្អប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៃការចំណាយថវិកា។

### *ការសង្កេតជាសេចក្តីសន្និដ្ឋានទី ១*

*ការដាក់បញ្ចូលគំនិតផ្តួចផ្តើមនៃការចូលរួមជាសាធារណៈ នៅក្នុងសេចក្តីព្រាងច្បាប់ថ្មីស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងសេចក្តីព្រាងច្បាប់ចុងក្រោយស្តីពីសិទ្ធិទទួលបានព័ត៌មានគួរតែត្រូវបានផ្តល់ការយកចិត្តទុកដាក់ខ្ពស់ជាប្រកចូលសម្រាប់កំណែទម្រង់អភិបាលកិច្ច។*

2. **ច្បាប់បោះឆ្នោត និងច្បាប់ស្តីពីគណបក្សនយោបាយ**ត្រូវបានកែប្រែដោយគណបក្សកាន់អំណាច។ ការវិវត្តទាក់ទងនឹងវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ បានផ្តល់អត្ថប្រយោជន៍ដល់ធាតុផ្សំនយោបាយមួយចំនួន។ **វិសោធនកម្មច្បាប់សហជីព ច្បាប់ស្តីពីសមាគមអង្គការមិនមែនរដ្ឋាភិបាល សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខតាមអ៊ីនធឺណិត និងច្បាប់ស្តីពីឧក្រិដ្ឋកម្ម ច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពមានអាសន្ន និងសណ្តាប់ធ្នាប់សាធារណៈ**ដែលធ្វើឡើងដោយគណបក្សកាន់អំណាចនៅតែស្ថិតក្នុងភាពចម្រូងចម្រាសនៅឡើយ។ ក្រោយមកមានការចោទប្រកាន់ជាបន្តបន្ទាប់លើសកម្មជនសង្គម និងបរិស្ថានក្រោមក្រមព្រហ្មទណ្ឌ ដែលកំណត់ដោយការជាប់ពាក់ព័ន្ធនយោបាយ ឬចលនាក្រៅច្បាប់

ប្រឆាំងនឹងរដ្ឋាភិបាលកំពុងផ្ទុះឡើង។ ការដាក់ឧបករណ៍នៃច្បាប់ផ្សេងៗមានសក្តានុពលបង្កើនទិដ្ឋភាពនៃ "នីតិរដ្ឋ" ។ **ការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌមួយចំនួន ដូចជាមាត្រា២៧ និង៤៩១ នៃក្រមព្រហ្មទណ្ឌ** បង្ហាញពីបរិយាកាស និងការសម្តែងនូវអំណាចជុំវិញប្រព័ន្ធតុលាការ ខណៈដែលបទប្បញ្ញត្តិផ្សេងទៀត ដូចជាអំពើក្បត់ជាតិ និងការញុះញង់ត្រូវបានប្រើប្រាស់ច្រើនដង ដើម្បីចាប់ និងកាត់ទោសអ្នកប្រឆាំងអ្នកកាន់អំណាច។

## *ការសង្កេតជាសេចក្តីសន្និដ្ឋានទី ២*

*សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យជាមូលដ្ឋាន (សេរីភាពក្នុងការបញ្ចេញមតិ ការជួបប្រជុំ និងសមាគម) ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គួរត្រូវបានយកចិត្តទុកដាក់តាមរយៈការបង្ហាញអំពីការរៀបចំគោលនយោបាយជាយុទ្ធសាស្ត្រ និងឧបករណ៍ច្បាប់ផ្សេងទៀត - គោលការណ៍ណែនាំប្រតិបត្តិការ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលគួរធានាឱ្យមានលំហសម្រាប់ពលរដ្ឋ សម្តែងសិទ្ធិបញ្ចេញមតិជាមូលដ្ឋាន ការគោរព សិទ្ធិសេរីភាពនៃការបង្កើតសមាគមនិងការពារការត្រួតពិនិត្យដោយអាជ្ញាធរនៅគ្រប់កម្រិតទៅលើការប្រមូលផ្តុំ។*

3. ការទទួលស្គាល់ថាផលប៉ះពាល់នាពេលបច្ចុប្បន្ន និងក្រោយ**កូវីដ-១៩ អាចបន្តរំខានដល់ការសិក្សា ជាប្រចាំក្នុងរយៈពេលយូរ**ហើយជាលទ្ធផលការស្វែងរកការអប់រំតាមសហគមន៍ដែលជាយន្តការជំនួសសម្រាប់ការសិក្សានេះអាចបន្តនៅក្នុងបរិបទក្រោយកូវីដ-១៩ ដើម្បីគាំទ្រកុមារឱ្យទទួលបាននូវការស្តារឡើងវិញនូវការអប់រំរបស់ពួកគេដែលបានបាត់បង់ ព្រមទាំងផ្តល់នូវការគាំទ្របន្ថែមដល់កុមារ ដែលមានសមត្ថភាពទាប និងផ្តល់លទ្ធភាពទទួលបានការអប់រំដល់កុមារដែលមានពិការភាពដើម្បីងាយស្រួលចូលប្រើប្រាស់សេវាគាំទ្រទាំងនោះ។ **រាជរដ្ឋាភិបាលកម្ពុជាបានព្យាយាមផ្តល់លទ្ធភាពឱ្យកុមារទាំង អស់បានត្រឡប់ទៅសាលារៀនវិញឱ្យបានឆាប់តាមដែលអាចមានសុវត្ថិភាព ក្នុងការធ្វើដូច្នេះ ជាពិសេសសម្រាប់សិស្សានុសិស្ស តាមសាលាមត្តេយ្យ សិក្សានិងសាលាបឋមសិក្សា។ នៅក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិការប្រកបដោយសុវត្ថិភាពនៃសាលារៀនក្នុងបរិបទនៃកូវីដ-១៩ នៅចុងឆ្នាំ២០២០។** ខណៈពេលដែល **រាជរដ្ឋាភិបាល និងឧស្សាហកម្មមានបំណងលើកកម្ពស់ជំនាញបដិវត្តន៍ឧស្សាហកម្មទី៤(4IR)** ការស្ទង់មតិរបស់និយោជកនៅក្នុងឧស្សាហកម្មកាត់ដេរ និងទេសចរណ៍បង្ហាញថា ទីមួយនិយោជកមានការយល់ដឹងតិចតួចអំពីបច្ចេកវិទ្យាបដិវត្តន៍ឧស្សាហកម្មទី៤(4IR)។ ទីពីរ លុះត្រាតែមានការវិនិយោគគ្រប់គ្រាន់ និងទាន់ពេលវេលាក្នុងការអភិវឌ្ឍន៍ជំនាញ នោះវាគ្មានការធានាថា កម្មកររបស់តនៅនឹងអាចផ្លាស់ទីយ៉ាងរលូនទៅក្នុងការ

ងារដែលបានបង្កើតថ្មីនោះទេ។ ទីបី ការងាររបស់តទំនងជាប៉ះពាល់ដល់ស្ត្រីដែលមានចំនួនប្រហែល៨១% នៃកម្លាំងពលកម្មផ្នែកកាត់ដេររបស់ប្រទេសកម្ពុជា។

## *ការសង្កេតជាសេចក្តីសន្និដ្ឋានទី ៣*

- *រាជរដ្ឋាភិបាលកម្ពុជាគួរតែធានាថា ការរៀនពីចម្ងាយប្រកបដោយគុណភាព បរិយាប័ន្ន និងមានតម្លៃសមរម្យ ត្រូវបានរៀបចំឡើងសម្រាប់កុមារទាំងអស់អាចចូលប្រើប្រាស់សេវានេះបានទាំងអស់គ្នា ដោយផ្តោតលើកុមារដែលងាយរងគ្រោះ និងខ្វះខាតបំផុត ដែលមិនអាចចូលប្រើប្រាស់សេវានៃគំនិតផ្តួចផ្តើមសិក្សាតាមអ៊ីនធឺណិតបាន។ ក្នុងន័យនេះគួរតែរួមបញ្ចូលនូវការបង្កើតកម្មវិធីអប់រំតាមទូរទស្សន៍ តាមវិទ្យុ និងកម្មវិធីអប់រំផ្អែកលើក្រដាស។*
- *វិធីសាស្ត្រថ្មីដើម្បីពង្រឹងការដាក់បញ្ចូល និងការគាំពារសង្គមសម្រាប់កម្មករនិយោជិតដែលទើបចូលបំរើការងារថ្មី ឬអ្នកដែលប្រឈមនឹងហានិភ័យនៃការផ្លាស់ប្តូរការងារ និងអ្នកដែលត្រូវការជំនាញបន្ថែម។ ការអភិវឌ្ឍន៍កម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈក្នុងវិស័យកាត់ដេរ និងទេសចរណ៍ជាមួយនឹងលិខិតសម្គាល់ជំនាញបដិវត្តន៍ឧស្សាហកម្មទី៤(4IR) និងកម្មវិធីវិញ្ញាបនប័ត្រជំនាញដែលអាចបត់បែនបាន និងម៉ូឌុលដែលទទួលស្គាល់នូវការទទួលបានជំនាញនៅខាងក្រៅបណ្តាញអប់រំបែបប្រពៃណី គួរតែត្រូវបានផ្តល់អាទិភាពខ្ពស់ នៅក្នុងពាក់កណ្តាលអាណត្តិក្រោយ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។*

4. ក្បាលម៉ាស៊ីននៃការរីកចម្រើនរបស់ប្រទេសគឺពឹងផ្អែកជាចម្បងលើ**វិស័យកាត់ដេរ សំណង់ ទេសចរណ៍ និងកសិកម្ម**។ ទោះជាយ៉ាងណាក៏ដោយ វិស័យទាំងនេះត្រូវបានរំខានដោយជំងឺរាតត្បាតចាប់តាំងពីដើមឆ្នាំ២០២០។ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតផែនការស្តារសេដ្ឋកិច្ចឆ្នាំ២០២១-២០២៣ដែលផ្តោតលើឧស្សាហកម្មតម្លៃខ្ពស់ កសិកម្ម ការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម ពាណិជ្ជកម្មឌីជីថល និងទេសចរណ៍។ **ច្បាប់ថវិកាសម្រាប់ឆ្នាំ២០២១ បានបង្ហាញលើការបែងចែកធនធានសម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាត និងការរស់រានមានជីវិត និងកំណើនសេដ្ឋកិច្ច**។ ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) បានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់ប្រាក់កម្ចី និងជំនួយឥតសំណងដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស និងការស្តារឡើងវិញពីជំងឺរាតត្បាត។ រាជរដ្ឋាភិបាលកម្ពុជាបានជំរុញយ៉ាងខ្លាំងក្លានូវថាមពលជំនួស ដើម្បីឆ្លើយតបទៅនឹងបញ្ហានៃការអភិវឌ្ឍន៍សេដ្ឋកិច្ចចម្រុះ ពោលគឺ ទំនប់វារីអគ្គិសនី និងរោងចក្រថាមពលពន្លឺព្រះអាទិត្យនៅទូទាំងប្រទេស។ **កម្រិតនៃការចូលរួមពីសហគមន៍ និងអង្គការសង្គមស៊ីវិលក្នុងគម្រោងទំនប់វារីអគ្គិសនីនៅតែមានការ**

រិះគន់នៅឡើយ។ ទំនងជាមិនមានយន្តការ និងឧបករណ៍ជាក់លាក់ណាមួយ ដើម្បីតាមដានផលប៉ះពាល់សង្គម និងបរិស្ថាននោះទេ។

### *ការសង្កេតជាសេចក្តីសន្និដ្ឋានទី ៤*

- *ការអនុវត្ត និងការអនុម័តវិធានការបន្ថែមទៀត ដើម្បីជំរុញការងើបឡើងវិញ និងការរស់ឡើងវិញនៃសេដ្ឋកិច្ច គួរតែគិតគូរពីតម្រូវការនៃជនងាយរងគ្រោះ ដែលកើនឡើងដោយជំងឺរាតត្បាត ប្រឈមមុខនឹងក្រុមផ្សេងៗ រួមមានស្ត្រី កុមារមានពិការភាព និងក្រុមជនជាតិដើមភាគតិច ដើម្បីទាញយកឱកាសដែលកំពុងមាន ដើម្បីបំពេញបន្ថែមដោយការបែងចែកធនធានប្រកបដោយសមធម៌ សម្រាប់ការទទួលបានជំនួយណាមួយចំពោះជំងឺរាតត្បាតកូវីដ-១៩ និងក្រោយសម័យកូវីដ-១៩។*
- *ក្រសួងបរិស្ថាន គួរតែធានាឱ្យមានការចូលរួមជាសាធារណៈពេញលេញ ក្នុងដំណើរការវាយតម្លៃផលប៉ះពាល់បរិស្ថាននៃគម្រោងអភិវឌ្ឍន៍ពីភាគីពាក់ព័ន្ធ រួមទាំងអង្គការសង្គមស៊ីវិល ជាពិសេសសហគមន៍មូលដ្ឋាន និងពន្លឿននូវដំណើរការតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA)។*

5. **វិស័យកសិកម្មទំនងជារងផលប៉ះពាល់តិចតួចដោយសារជំងឺរាតត្បាត ប៉ុន្តែផ្ទុយទៅវិញវាមានការកើនឡើងនូវឱកាសក្នុងការវិនិយោគបន្ថែមទៀត។** ជនចំណាកស្រុកដែលវិលត្រឡប់មកវិញ កម្មករដែលត្រូវបានព្យួរការងារ ឬនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារ បានមើលឃើញថា ផលិតកម្មកសិកម្ម គឺជាជម្រើសរបស់ពួកគេក្នុងការប្រកបរបរចិញ្ចឹមជីវិត បន្ទាប់ពីប្រភពចំណូលបំបងរបស់ពួកគេត្រូវបានរាំងស្ទះដោយជំងឺរាតត្បាត។ **មានប្រព័ន្ធធារាសាស្ត្រត្រូវបានសាងសង់ ប៉ុន្តែភាគច្រើនមិនទាន់បានពេញលេញនៅឡើយ ដែលធ្វើឱ្យកសិករខ្វះលទ្ធភាពទទួលបានប្រភពទឹកសំខាន់សម្រាប់ស្រោចស្រពកសិដ្ឋានរបស់ពួកគេ។ ធនធានធម្មជាតិត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយវិសាលភាពនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលបានខិតខំប្រឹងប្រែងបង្កើត និងពង្រីកព្រៃសហគមន៍/តំបន់ការពារ ដើម្បីកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ។** ទោះយ៉ាងណាក៏ដោយ បញ្ហាប្រឈមនៅតែមាន ដែលត្រូវយកចិត្តទុកដាក់ក្នុងការកាត់បន្ថយបន្ថែមទៀត។

## ការសង្កេតជាសេចក្តីសន្និដ្ឋានទី ៥

- *គួរវាយតម្លៃបន្ថែមលើសក្តានុពលផលិតកម្មកសិកម្ម និងកិច្ចសហការយ៉ាងជិតស្និទ្ធរវាងក្រសួងពាក់ព័ន្ធចាំបាច់ត្រូវមានជាក្របខ័ណ្ឌច្បាប់ និងវិធីសាស្ត្រជាប្រព័ន្ធបន្ថែមទៀត ដើម្បីញ៉ាំងអាទិភាពនៃការអភិវឌ្ឍធនធានទឹកអាចឆ្លើយតបទៅនឹងតម្រូវការផ្គត់ផ្គង់ទឹក ដើម្បីទាញយកសក្តានុពលផលិតកម្មកសិកម្មជាអតិបរិមា។*
- *រាជរដ្ឋាភិបាលកម្ពុជាគួរតែជំរុញឱ្យមានការចូលរួម និងការគាំទ្រពីភាគីពាក់ព័ន្ធទាំងអស់ខណៈពេលដែលពិនិត្យមើលច្បាប់ និងបទប្បញ្ញត្តិទាក់ទងនឹងដីធ្លី ដើម្បីធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់ និងបង្កើតច្បាប់ ឬស្តង់ដារច្បាប់ ដែលមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។ ការអនុវត្តច្បាប់នៅក្នុងទិដ្ឋភាពពិសេសនេះគួរតែត្រូវបានកែលម្អបន្ថែមទៀត តាមរយៈការផ្ទេរមុខងារដែលបានកំណត់យ៉ាងច្បាស់ទៅថ្នាក់ក្រោមជាតិរួមទាំងឃុំ/សង្កាត់។*
- *ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ គួរបន្តពង្រឹងយន្តការសុរិយោដី នៃក្រុមការងារដោះស្រាយវិវាទដីធ្លី ឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការផ្តល់ធនធានគ្រប់គ្រាន់ និងជំរុញឱ្យមានការស៊ើបអង្កេតនូវរាល់ករណីជម្លោះនីមួយៗ។*
- *រាជរដ្ឋាភិបាលកម្ពុជាគួរតែពិចារណារៀបចំគោលនយោបាយជាតិស្តីពីសំណង់សមរម្យ និងលំនៅស្ថានសមរម្យ ដើម្បីដោះស្រាយផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍ទាំងឯកជន និងសាធារណៈ ដើម្បីបំពេញតម្រូវការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេស ដោះស្រាយបញ្ហាដែលកំពុងកើតមាន និងសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ។*

សូមអរគុណ!